**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/២/០៧-០៩-២០០៩-អវតក/អជសង
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / 01 / 2020
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ អមដោយ ឧបសម្ព័ន្ធសម្ងាត់**
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

## សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ក

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រមម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រមម Martin KAROPKIN
ចៅក្រម យូរ ឧត្តរា

**សហមេធាវី អោ អាន:**
លោក មុំ លុផ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**
**នៃសំណុំរឿង ០០៤/២**

## I. សេចក្តីផ្តើម

1. អនុលោមវិធាន៨០ នៃវិធានផ្ទៃក្នុង សម្រាប់ អ.វ.ត.ក[1] សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួនចំនួន ១២៦នាក់ ដែលខ្លួនមានបំណងចង់កោះហៅសម្រាប់ការជំនុំជម្រះ អោ អាន។ បញ្ជីនេះមាននៅក្នុងឧបសម្ព័ន្ធសម្ងាត់ដែលបានភ្ជាប់ទៅជាមួយនឹងសារណានេះ (**ឧបសម្ព័ន្ធសម្ងាត់ ១**)។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសន្និដ្ឋានផ្នែកច្បាប់ខុសៗគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប ("ស.ច.ស") ក្រោយពីបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនទៅលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹង អោ អាន[2]។ ចៅក្រមបីរូបបានសម្រេចតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ និងបានមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ[3] ចំណែកចៅក្រមពីររូបផ្សេងទៀត បានសម្រេចទុកជាមោឃៈដីកាសម្រេចលើកលែងចោទប្រកាន់ និងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4]។ ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុប ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែមានសុពលភាព និងថាបើដូច្នេះ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង សំណុំរឿងនេះត្រូវបានប្តឹងទៅ អ.ជ.ស.ដ ដោយផ្អែកតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[5]។

---

[1] អង្គជំនុំជម្រះសាលាដំបូងក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន")។

[2] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩ ("សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ")។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ និងឲ្យបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ចំណែកសហចៅក្រមស៊ើបអង្កេតជាតិ បានលើកលែងចោទប្រកាន់ប្រឆាំងនឹងគាត់។ *សូមមើល* ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[3] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៧០-៣០២ ("យោបល់របស់ចៅក្រមជាតិ")។

[4] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៤-៦៩៤ ("យោបល់របស់ចៅក្រមអន្តរជាតិ") ជាពិសេស កថាខណ្ឌ ៦៨២-៦៨៤។

[5] ឯកសារ **D359/24 & D360/33** យោបល់របស់ចៅក្រមអន្តរជាតិ ផ្នែកសម្រេចសេចក្តី ត្រង់ KH 01635147។

3. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស.ព.អ បានស្នើអង្គជំនុំជម្រះនេះឱ្យ (i) ពន្យាររយៈពេលកំណត់ ១៥ ថ្ងៃ ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន ដែលខ្លួនមានបំណងចង់កោះហៅសម្រាប់ការជំនុំជម្រះ និង (ii) បើកកិច្ចប្រជុំរៀបចំសវនាការ ("សំណើ")[6]។

## III. ច្បាប់ជាធរមាន

4. វិធាន ១(២) នៃវិធានផ្ទៃក្នុង ចែងថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះសំដៅទៅដល់សហព្រះរាជអាជ្ញា គឺរួមបញ្ចូលសហព្រះរាជអាជ្ញាទាំងពីររូប ដែលធ្វើការសម្រេចរួមគ្នា និងសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ"។

5. វិធាន ៨០(១) នៃវិធានផ្ទៃក្នុងចែងថា ដើម្បីត្រៀមរៀបចំសវនាការ៖

> សហព្រះរាជអាជ្ញា ត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលា ដំបូងនូវបញ្ជីឈ្មោះសាក្សី រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិណាមួយដែលមានចែងនៅក្នុងវិធាន ២៤(២) និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ ក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនឯកសារថតចម្លងមួយច្បាប់ទៅឱ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ។

6. វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ចែងថា "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន [...] អង្គជំនុំជម្រះអាច ក- ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់"។

7. មាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក[7] ធានាឱ្យមានការគោរពចំពោះការការពារជនរងគ្រោះ និងសាក្សី ដោយចែងថា៖

---

[6] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់សម្រាប់ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ (សំណើនេះមិនទាន់ត្រូវបានជូនដំណឹងជាផ្លូវការនៅឡើយ)។

[7] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានធ្វើវិសោធនកម្មថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)។

"អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី"។

8. បន្ថែមលើនេះ វិធាន ២៩(៣) ចែងថា៖

តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬ តាមពាក្យសុំ និងក្រោយពេលពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ ឬ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់វិធានការសមស្រប ដើម្បីការពារអ្នកប្តឹងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមកបង្ហាញខ្លួន ប្រសិនបើការបង្ហាញខ្លួននោះអាចធ្វើឲ្យអាយុជីវិត សុខមាលភាព ឬ ក្រុមគ្រួសារ ឬ ញាតិជិតស្និទ្ធរបស់ពួកគេត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចេញដីកាបែបនេះ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ក្នុងករណីដែលមានការបង្ហាញអំពីហានិភ័យបែបនេះនៅក្នុងសំណុំរឿង។ វិធានការការពារសម្រាប់សាក្សីត្រូវស្នើសុំយ៉ាងយូរ១៥ថ្ងៃ ក្រោយពីដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។ នៅដំណាក់កាលជំនុំជម្រះ វិធានការការពារសម្រាប់សាក្សី ត្រូវស្នើសុំយ៉ាងយូរត្រឹមថ្ងៃដាក់បញ្ជីឈ្មោះសាក្សី ដូចដែលមានចែងក្នុងវិធាន៨០។ ក្នុងករណីពិសេស អង្គជំនុំជម្រះអាចពិចារណាលើពាក្យសុំដែលដាក់យឺតបាន។

9. ជាងនេះទៀត មាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មាន[8] ទាក់ទងនឹងសំណុំរឿង ចែងថា៖

ដើម្បីការពារសាក្សីឲ្យមានប្រសិទ្ធិភាព នៅក្នុងដំណាក់កាលបន្តបន្ទាប់នៃកិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការសាធារណៈ និងការដាក់ឯកសារដែលបានដាក់មុនការយកចម្លើយសាក្សីម្នាក់ៗ សាក្សីនឹងត្រូវបានយោងដោយប្រើលេខសំគាល់ អក្សរកាត់រហស្សនាម ឬតាមមធ្យោយផ្សេងៗតាមករណីសមស្រប។ សាក្សីអាចបោះបង់សិទ្ធិរបស់ខ្លួនដែលចែងក្នុងកថាខណ្ឌនេះជាលាយល័ក្ខណ៍អក្សរ។

[8] សេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (សេចក្តីណែនាំអនុវត្ត ០០៤/២០០៩), ដែលបានកែប្រែនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩។

## IV. សារណា

*ការកំណត់ពេលវេលានៃការដាក់បញ្ជី*

10. ដោយហេតុថាការពិចារណារបស់ អ.ប.ជ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានចូលជាស្ថាពរនៅកាលបរិច្ឆេទនោះ។ ដោយអនុលោមតាមវិធាន ៨០(១) និង ១(២) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា ដែលបំពេញកិច្ចរួមគ្នា ឬដាច់ដោយឡែកពីគ្នា តម្រូវឱ្យដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន ជូនទៅក្រឡាបញ្ជីរបស់ អ.ជ.ស.ដ ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។ ជាវិបាក បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ ស.ព.អ ត្រូវដល់កាលកំណត់ដាក់នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ តាមសេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់ខ្លួន។ ដោយហេតុថា អ.ជ.ស.ដ មិនទាន់បានសម្រេចលើសំណើនេះ គិតត្រឹមពេលដាក់បញ្ជីនេះ ស.ព.អ សូមដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួនស្របតាមសំណើ និងសម្រាប់មូលហេតុនានាដូចបានផ្តល់ជូនខាងក្នុងនេះ។

*ការជ្រើសរើសសាក្សី និងអ្នកជំនាញ*

11. បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ត្រូវបានដាក់ទៅតាមលំដាប់តួអក្សរនៅក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១**។ ដើម្បីជាប្រយោជន៍នៃភាពពេញលេញ ក្នុងករណីដែល ស.ព.អ ចង់កោះហៅបុគ្គលណាម្នាក់ឱ្យផ្តល់សក្ខីកម្ម ហើយបុគ្គលនោះជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") បុគ្គលនេះត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ និងត្រូវបានកំណត់បែបដូច្នោះ។ បុគ្គលនានានៅក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១** មិនទាន់ត្រូវបានទាក់ទងដោយ ស.ព.អ ដើម្បីកំណត់ថាតើពួកគេមានទំនាក់ទំនង ដូចដែលបានយោងនៅក្នុងវិធាន ២៤(២) នៃវិធានផ្ទៃក្នុងឡើយ ដូច្នេះ ចាំបាច់នឹងត្រូវធ្វើការស្វែងរកព័ត៌មានបន្ថែមទៀត។

12. ដើម្បីឱ្យទាន់ពេលវេលា និងអនុលោមតាមការបង្គាប់បន្ថែមរបស់ អ.ជ.ស.ដ ស.ព.អ នឹងដាក់លំដាប់ហៅសាក្សី និងអ្នកជំនាញដែលខ្លួនស្នើសុំឱ្យកោះហៅ ដើម្បីជួយធានាថាឱ្យមានការបង្ហាញប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល នៃរឿងក្តីរបស់អយ្យាការ។ សាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្នើឡើងក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ជាក់នូវអង្គហេតុនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងជួយសម្រួលដល់ភាពចាំបាច់សម្រាប់សេដ្ឋកិច្ចតុលាការ។

13. សាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន មិនត្រូវបានដាក់នៅក្នុងបញ្ជីឈ្មោះនេះទេ ដោយមូលហេតុដែលថា អយ្យការនឹងត្រូវបានអនុញ្ញាតឲ្យដាក់បញ្ចូលទៅក្នុងភស្តុតាងនូវ ចម្លើយពីមុន និងឯកសារពាក់ព័ន្ធផ្សេងៗរបស់ពួកគេ អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណា ក្នុងករណីដែលឯកសារទាំងនេះមិនត្រូវបានទទួលយក ស.ព.អ សូមជូនដំណឹងដល់ អ.ជ.ស.ដ ថា គាត់អាចស្នើសុំបុគ្គលបន្ថែមទៀតឲ្យមកផ្តល់សក្ខីកម្ម ដើម្បីបំពេញទៅតាមបន្ទុកនៃការបង្ហាញភស្តុតាងនៅក្នុងរឿងក្តីនេះ។ ឧទាហរណ៍ ស.ព.អ មិនបានដាក់បញ្ចូលបុគ្គលទាំងអស់ដែលអាចជួយដល់ការបញ្ជាក់យថាភូតនៃឯកសារពាក់ព័ន្ធ ដែលនឹងត្រូវស្វែងរកឲ្យទទួលយកនោះទេ។ ប្រសិនបើមេធាវីការពារក្តីជំទាស់នឹងការបញ្ជាក់យថាភូតនៃឯកសារដូច្នេះណាមួយនោះ ហើយ អ.ជ.ស.ដ កំណត់ថា ការបញ្ជាក់យថាភូតបន្ថែមទៀត ត្រូវបានតម្រូវឲ្យមាននោះ អយ្យការនឹងស្នើសុំឲ្យមានការកោះហៅសាក្សីដើម្បីបញ្ជាក់យថាភូតបន្ថែមទៀត។

14. ស្រដៀងគ្នានេះ ក្នុងករណីដែលសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១** មិនអាចបង្ហាញខ្លួននៅពេលជំនុំជម្រះបានដោយមូលហេតុណាមួយ ឬប្រសិនបើពួកគេបង្ហាញខ្លួននៅពេលជំនុំជម្រះ ហើយមិនអាចបង្ហាញអង្គហេតុដែលមាននៅក្នុងចម្លើយពីមុនរបស់ពួកគេ ស.ព.អ ក៏ផ្តល់ឲ្យផងដែរនូវការកត់សម្គាល់ទៅកាន់ អ.ជ.ស.ដ ថា គាត់អាចស្នើសុំថា សាក្សី អ្នកជំនាញ ឬដើម្បបណ្តឹងរដ្ឋប្បវេណីជំនួសនឹងត្រូវកោះហៅឲ្យមកបង្ហាញខ្លួន ដើម្បីផ្តល់សក្សីកម្មលើបញ្ហាដូចគ្នា ឬស្រដៀងគ្នានេះ។

15. កាន់តែទូលំទូលាយជាងនេះទៀត ក្នុងខណៈពេលដំណាក់កាលរៀបចំសវនាការ និងការជំនុំជម្រះរីកចម្រើនទៅមុខ ហើយគេជឿថា ចាំបាច់ត្រូវកោះហៅសាក្សីបន្ថែមសម្រាប់បញ្ហាជាក់លាក់ណាមួយ ដើម្បីបំពេញបន្ទុកនៃការបង្ហាញភស្តុតាងរបស់អយ្យការនោះ ស.ព.អ ផ្តល់ការកត់សម្គាល់ទៅកាន់ អ.ជ.ស.ដ ថា គាត់នឹងធ្វើសំណើដូច្នេះ នៅពេលណាមានការជឿជាក់បែបនោះ។

### *វិធានការការពារ*

16. ខណៈដែលសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១** មិនទាន់ត្រូវបានទាក់ទងដោយ ស.ព.អ នោះ គាត់មិនអាចនិយាយបានថា តើបុគ្គលណាមួយដែលត្រូវបានរៀបរាប់ក្នុងបញ្ជី អាចត្រូវការវិធានការការពារនៅពេលជំនុំជម្រះឡើយ។ អាស្រ័យហេតុនេះ គាត់ស្នើសុំឲ្យរក្សាការសម្ងាត់ចំពោះអត្តសញ្ញាណរបស់បុគ្គលទាំងនេះ រហូតទាល់តែឋានៈបច្ចុប្បន្នរបស់ពួកគេស្តីពីវិធានការការពារអាចត្រូវបានបញ្ជាក់។

17. អនុលោមតាមមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង និងដោយសារអង្គហេតុដែលថា សហព្រះរាជអាជ្ញាមិនបានទាក់ទងជាមួយនឹងអ្នកជំនាញ សាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលមានរៀបរាប់ក្នុងបញ្ជីនេះ ស.ព.អ ស្នើសុំថា អ.ជ.ស.ជ បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") និងផ្នែកគាំពារជនរងគ្រោះ ("VSS") ជួយគាត់ក្នុងការកំណត់ថាតើ វិធានការការពារគួរត្រូវបានស្វែងរកសម្រាប់បុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជីរបស់ ស.ព.អ ឬទេ។ ក៏សុំស្នើផងដែរឲ្យអង្គភាពទាំងអស់នេះ ស្វែងរកព័ត៌មានជាក់លាក់អំពីសាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ ចំពោះប្រភេទការការពារដែលពួកគេអាចជឿជាក់ថាចាំបាច់។

18. ស្របទៅនឹងមាត្រា ៧ នៃសេចក្ដីណែនាំអនុវត្តស្ដីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ស.ព.អ ស្នើសុំថា បុគ្គលដែលមានឈ្មោះក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១** ត្រូវយោងសំដៅដោយរហស្សនាមដែលដាក់ឲ្យ។ សុំស្នើថា រហស្សនាមទាំងនេះត្រូវប្រើនៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល រហូតទាល់តែការសម្រេចត្រូវបានធ្វើឡើងដោយ អ.ជ.ស.ជ ទាក់ទងនឹងភាពចាំបាច់នៃវិធានការការពារ។ ការណ៍នេះនឹងផ្ដល់នូវការការពារភ្លាមៗសម្រាប់កង្វល់អំពីបញ្ហាសន្តិសុខដែលអាចមានរបស់បុគ្គលណាមួយ។ រហស្សនាមទាំងនេះត្រូវបានកំណត់ដោយអក្សរ "ព៤/២" ដោយមានបីខ្ទង់ខាងក្រោយ ឧទាហរណ៍ "ព៤/២-០០១"។ រហស្សនាមទាំងនេះត្រូវបានដាក់ជាបន្តបន្ទាប់ស្របតាមលំដាប់អក្សរក្នុងបញ្ជី។

## V. ឧបាស្រ័យដែលស្នើសុំ

19. អាស្រ័យដូចមូលហេតុដែលបានរៀបរាប់ខាងលើ ស.ព.អ សូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួនក្នុងសំណុំរឿង។

(២) បង្គាប់ឲ្យអង្គភាព WESU និងផ្នែក VSS ផ្ដល់ព័ត៌មានទាំងអស់ដែលចាំបាច់ឲ្យទៅ អ.ជ.ស.ជ និងភាគីនានា ដើម្បីធ្វើសេចក្ដីសម្រេច ឬ សំណើសុំចាំបាច់ណាមួយទាក់ទងនឹងការការពារសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីនៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងអស់នេះ។

(៣) ដាក់រហស្សនាមដែលបានសន្មត់ឲ្យសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុង **ឧបសម្ព័ន្ធសម្ងាត់ ១** និងណែនាំភាគីនានាឲ្យប្រើរហស្សនាមទាំងអស់នេះ នៅពេលដែលកំណត់អត្តសញ្ញាណបុគ្គលទាំងនេះជាសាធារណៈ រហូតទាល់តែដល់ពេលដែលថាការការពារបន្ថែមទៀតត្រូវបានធ្វើឡើង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ | **លោកស្រី** **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |